# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
# សាលាបឋមសិក្សាចំណេះទូទៅ




## ចំណេះដឹងទូទៅថ្នាក់ទី១ និងទី២

- វគ្គភាសាអង់គ្លេស
- វគ្គកុំព្យូទ័រ

# គោលបំណង

- ជួយអោយពួកគេមានមូលដ្ឋានគ្រឹះថ្នាកទី១ និងទី២ ដើម្បីបន្តការសិក្សា នៅបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ឬមហាវិទ្យាល័យដូចកុមារទូទៅ
- ជួយអោយពួកគេមានមូលដ្ឋានគ្រឹះថ្នាក់ភាសាអង់គ្លេស និងកុំព្យូទ័រ
- សម្រាប់ឆ្នាំទី៣ និងទី៤
- សំរាប់អនាគតការងារនៅក្នុងសង្គម
- ជួយអោយពួកគេរៀនអប់រំជំនឿនិងចូលរួមសកម្មភាពព្រះសហគមន៍ផ្សេងៗ
- សំរាប់ប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ
- ពួកគេអាចប្រើភាសាខ្មែរសំរាប់របរចិញ្ចឹមជីវិត

# ប្រវត្តិ នៃការកកើត កម្មវិធីអក្ខរកម្មភាសាខ្មែរ សំរាប់កុមារគ្រីគ្រា និងកុមារវៀតណាម

ប្រវត្តិនៃការកកើតកម្មវិធីអក្ខរកម្មភាសាខ្មែរនេះ បានចាប់ផ្តើមតាំងពីឆ្នាំ ១៩៩៥ ក្រោមការជួយឧបត្ថម្ភពី អង្គការ (COERR) ពីប្រទេសថៃ។ ដំណើរការដំបូង មាន១៦សហគមន៍វៀតណាម ទូទាំងភូមិភាគភ្នំពេញ មានក្នុងខេត្ត ព្រៃវែង កណ្តាល និងរាជធានីភ្នំពេញ ។សហគមន៍ទាំងនោះជាព្រះសហគមន៍កាតូលិក ។អង្គការ(COERR) បាន ផ្តល់ជំនួយឧបត្ថម្ភជាថវិការរហូតដល់ឆ្នាំ២០០៣ដោយយល់ឃើញថា ព្រះសហគ-មន៍កាតូលិកយើងមានការរីកចំរើនអាចបន្តទទួលខុសត្រូវលើគម្រោងនេះបាន ។ចាប់តាំងពីឆ្នាំ២០០៤មក ព្រះសហគមន៍បានទទួលខុសត្រូវ ទាំងស្រុងលើគម្រោងនេះ និងបាន ពង្រីកគម្រោងរហូតដល់ ២២សហគមន៍ ស្ថិតនៅក្រោមការឧបត្ថម្ភដោយ ភូមិភាគភ្នំពេញ និងក្រោមការណែនាំដោយលោកអភិបាល អេមីល ដេតម្ប ។

ក្នុងឆ្នាំ២០០៩ សហគមន៍កោះទៀវបានបិទ ដោយសារគ្មានកុមារមកចុះឈ្មោះចូលរៀន បន្ទាប់ពីកម្មវិធីបានបញ្ជូនសិស្សមួយចំនួនចូលរៀនសាលារដ្ឋាភិបាល (សាលាបឋមសិក្សាក្បាលកោះ)។ ឆ្នាំ២០១០ លោក អភិបាលអូលីវីយេ ត្រូវបានតែងតាំងជាអភិបាលភូមិភាគភ្នំពេញ។ លោកបានយកចិត្តទុកដាក់ខ្ពស់ទៅលើគម្រោងនេះ ហើយលោកបានអនុញ្ញាតអោយបើក ដំណើរការសហគមន៍កោះទៀវឡើងវិញ និង បានបើកសាលាថ្មីៗបន្តបន្ទាប់ ដូចជាៈសហគមន៍ទួលក្រសាំង និងបានដាក់សហគមន៍អ្នកលឿង និងស្ទឹងស្លូត ក្រោមការគ្រប់គ្រងរបស់ភូមិភាគកំពង់ចាម។ រហូតមកដល់សព្វថ្ងៃយើងមានសហគមន៍កំពុងដំណើរការគម្រោងអក្ខរកម្មទាំងអស់សរុបចំនួន ២១ សហគមន៍ មានដូចជាៈ កំពង់ចម្លង កោះទៀវ កោះនរា គីឡូលេខ៩ ចាក់អង្រែក្រោម ចំប៉ា ជ្រៃធំ ដីឥដ្ឋ ទួលក្រសាំង ទួលតាំង ផ្លូវត្រី ព្រែកដាច់ ពោធិតុង ពោធិបាន ភូមិតាហ៊ីង មាត់ក្រសាស់ ស្អាង ស្វាយប៉ាក ស្វាយរលំ សំរោងធំ និងអរិយ៍ក្សត្រ។

ក្នុងឆ្នាំសិក្សា២០១២-២០១៣កម្មវិធីបានបញ្ជូនសិស្សចំនួន១៩២នាក់ សិស្សស្រីចំនួន៩៦នាក់ទៅបន្តការសិក្សាជាមួយសាលារដ្ឋាភិបាល។ កម្មវិធីអក្ខរកម្មពីមួយថ្ងៃ ទៅមួយថ្ងៃ បានកែប្រែកម្មសិក្សារបស់ខ្លួន ឲ្យស្របទៅ តាមកម្មវិធីសិក្សារបស់រដ្ឋ (កម្មវិធីសិក្សាពីថ្នាក់ទី១ដល់ទី៣)។ ដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្ស ពេលបញ្ចប់ ការសិក្សារបស់ខ្លួនត្រឹមថ្នាក់ទី៣ជាមួយកម្មវិធី អាចបន្តការសិក្សាជាមួយសាលារដ្ឋបាន។ ចំណែកថ្នាក់រៀនបានផ្លួសផ្លុលកែលំអឲ្យមានលក្ខណៈល្អប្រសើរធ្វើឲ្យសិស្សចង់រៀនសូត្រ

ពេលមានថ្នាក់រៀនស្អាត និងមានខ្យល់ អាកាសចេញចូលល្អ។ ជាទូទៅទៅយើងតែងតែរើសគ្រូពីសាលារដ្ឋ និងគ្រូចូលនិវត្តន៍ មិនតែប៉ុណ្ណោះយើង បានជ្រើសរើសយុវជនដែលធ្លាប់បំរើការងារ ឲ្យព្រះសហគមន៍ផងដែរ។ យើងចង់បង្ហាញឲ្យឪពុកម្តាយរបស់ពួកគេបានឃើញពីតម្លៃនៃការសិក្សារៀនសូត្ររបស់កូនចៅពួកគេ។ កាលណាពួកគេមានចំណេះវិជ្ជា មិនខ្វះការងារធ្វើ មានប្រាក់ខែអាច ចិញ្ចឹមជីវិតរបស់ពួកគេបាន។

ទោះបីយើងឃើញលទ្ធផលនៃកម្មវិធីខាងលើបានល្អ ប៉ុន្តែនៅតែមានកាខ្វះខាតមួយចំនួនដែលនាំឲ្យរាំងដល់ ដំណើរការក្នុងការអភិវឌ្ឍន៍នាពេលអនាគតវែងឆ្ងាយ។ ឧបសគ្គទាំងនោះមានដូចជា៖

- *ម៉ោងបង្រៀនតិចពេក*
- *កម្មវិធីបង្រៀនតិចជាងកម្មវិធីរបស់សាលារដ្ឋ*
- *មិនសូវទទួលការគាំទ្រ និងទុកចិត្តពីឪពុកម្តាយរបស់កុមារ*
- *កុមារមិនបានទៅបន្តការសិក្សានៅសាលារដ្ឋទាំងអស់ ក្រោយពីបញ្ចប់ពីកម្មវិធីអក្ខរកម្ម។*

ដោយសារតែឃើញនូវបញ្ហាខាងលើ ទើបលោកអភិបាល អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានបំណងបង្កើតសាលាបឋមសិក្សាមានថ្នាក់ទី ១ និងទី២ ជាប់នឹងសហគមន៍ ដែលជាប់នឹងព្រះវិហារកាតូលិក ដោយប្រើប្រាស់ថ្នាក់និងសំភារៈរបស់អក្ខរកម្ម រួមនឹងបន្ទប់ផ្សេងៗក្នុងព្រះវិហារមានស្រាប់។ គម្រោង សាលាបឋមមាននៅក្នុងសហគមន៍ដែលធ្លាប់មានថ្នាក់អក្ខរកម្មពីមុនចំនួន១៤តំបន់។

កម្មវិធីសាលាបឋមសិក្សាព្រះសហគមន៍កាតូលិកមានពីថ្នាក់ ទី១ និងទី២ បានបែងចែកជាពីរតំបន់ដូចជា៖

១/ តំបន់ភ្នំពេញ មានសាលាចំនួន ៤កន្លែង ដែលមានសាលាចំប៉ាជាមេ ឯសាលាផ្សេងទៀតជាសាខា មានដូចជា៖ ទួលតាំង កោះនរា និង ស្វាប៉ាក។

២/ តំបន់ខេត្តកណ្តាល មានសាលាចំនួន ១០កន្លែង ដែលមានសាលាសំរោងធំជាមេ ឯសាលាផ្សេងទៀតជាសាខា មានដូចជា៖ តាមទន្លេមេគង្គមាន (រោងចក្រផ្លូវត្រី កំពង់ចំលង ព្រៃដាច់) និងតាមទន្លេបាសាក់ មាន (បឹងឈូក ទួលក្រសាំង ស្អាងសំប៉ាន និងជ្រៃធំ)។

# រចនាសម្ព័ន្ធសាលាបឋមសិក្សាព្រះសហគមន៍កាតូលិកចំប៉ា



# បទបញ្ជាផ្ទៃក្នុងសម្រាប់សិស្ស

ប្រការ១: សិស្សានុសិស្សត្រូវមករៀនឲ្យបានទៀងទាត់ និងទាន់ពេល វេលាដែលសាលាបានកំណត់ (ក្នុងករណីមកយឺតលើសពី១៥នាទីឡើងទៅ សិស្សត្រូវទៅសុំការអនុញ្ញាតពីការិយាល័យ)។

ប្រការ២: សិស្សទាំងអស់ត្រូវស្លៀកពាក់ឯកសណ្ឋានជានិច្ច (អាវស សំពត់ ខោខ្មៅ ឬខៀវ) កាត់ សក់ឲ្យ បានសមរម្យ (ពណ៌ខ្មៅ ឬតាមពណ៌ធម្មជាតិ ហាមលាបពណ៌) ក្រចកត្រូវកាត់ ឲ្យខ្លី និងហាមលាបពណ៌។

ប្រការ៣: ភាពឆើតឆាយ និងគ្រឿងអលង្ការផ្សេងៗ ព្រមទាំងសម្ភារៈមានតម្លៃ ពាក់វ៉ែនតាខ្មៅ ពាក់មួក ពាក់ក្រវិល (សិស្សប្រុស) និងពាក់ក្រវិលច្រើនជាន់ (សិស្សស្រី) ត្រូវបានហាម ឃាត់ក្នុងបរិវេណ សាលា ករណីបាត់បង់សាលាមិនទទួលខុសត្រូវឡើយ។

ប្រការ៤: សិស្សានុសិស្សត្រូវប្រកាន់ជាប់នូវអាកប្បកិរិយាស្លូតបូត សុភាពរាបសារ និងសមរម្យ ចំពោះ លោកគ្រូ-អ្នកគ្រូ ចាស់ព្រឹទ្ធាចារ្យ និងមិត្តរួមថ្នាក់។ នៅពេលលោកគ្រូ-អ្នកគ្រូ ឬភ្ញៀវចូលក្នុងថ្នាក់ និងចេញពីថ្នាក់ សិស្សត្រូវក្រោកឈរដោយស្ងៀមស្ងាត់។

ប្រការ៥: ពេលលោកគ្រូ-អ្នកគ្រូមិនមានវត្តមាននៅក្នុងថ្នាក់ សិស្សទាំងអស់ត្រូវរក្សាភាពស្ងៀមស្ងាត់ មិនត្រូវមាត់ឡូឡារំខានដល់ថ្នាក់ដទៃ។

ប្រការ៦: រាល់ពេលចេញលេងមិនត្រូវលេងល្បែងអ្វីដែលរំខានដល់ថ្នាក់ដទៃ និងសិស្សដទៃ។

ប្រការ៧: សិស្សានុសិស្សទាំងអស់ត្រូវចេះសាមគ្គីគ្នា ចេះអធ្យាស្រ័យឲ្យគ្នា ចេះស្រឡាញ់គ្នាទៅវិញទៅមក ដូចជាបងប្អូន ត្រូវជៀសវាងទំនាស់ផ្សេងៗក្នុងបរិវេណសាលាជាដាច់ខាត។ ត្រូវរាយការណ៍ជូន លោកគ្រូ-អ្នកគ្រូ ឬសាលានៅពេលបានទទួលដំណឹង ឬឃើញ ហេតុការណ៍មិនប្រក្រតីកើតឡើង ដោយប្រការណាមួយ។

ប្រការ៨: ត្រូវចូលរួមផ្តល់យោបល់ក្នុងន័យស្ថាបនា ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សាលាយើង ទាំង អស់គ្នា។

ប្រការ៩: ក្នុងពេលកំពុងសិក្សា ហាមបរិភោគចំណី និងភេសជ្ជៈផ្សេងៗ ត្រូវអង្គុយឲ្យស្ងៀមស្ងាត់ ដោយ ឥរិយាបទសមរម្យ និងយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់។ រាល់ការបរិភោគចំណី អាហាររួចត្រូវ ចោលសម្រាមក្នុងធុងសម្រាម។

ប្រការ១០: ក្នុងម៉ោងសិក្សា មិនអនុញ្ញាតឲ្យប្រើប្រាស់ទូរស័ព្ទ និងសម្ភារៈអេឡិចត្រូនិចផ្សេងៗ ដែលរំខានដល់ការសិក្សា។

ប្រការ១១: ហាមនាំយកអាវុធជាតិផ្ទុះគ្រប់ប្រភេទ គ្រឿងញៀន គ្រឿងស្រវឹង និង

ល្បែងស៊ីសងចូលក្នុងសាលាជាដាច់ខាត។

ប្រការ១២: សិស្សដែលរៀនបឋមសិក្សាត្រូវនៅលីវ។

ប្រការ១៣: សិស្សមិនត្រូវធ្វើអ្វីដែលប៉ះពាល់ដល់ច្បាប់រដ្ឋ និង ប្រពៃណីទំនៀមទំលាប់ដ៏ល្អរបស់ជាតិ។

ប្រការ១៤: សិស្សត្រូវធ្វើកិច្ចការដែលគ្រូដាក់ឲ្យ និងប្រគល់ឲ្យគ្រូវិញ ជាមួយនឹងហត្ថលេខាពីមាតា បិតា ឬអាណាព្យាបាលសិស្ស។ សិស្សឈប់ឥតច្បាប់ ឬមានច្បាប់ក្នុងពេលប្រលង ឆមាសចាប់ពី ៣មុខវិជ្ជា មិនត្រូវបានចំណាប់ថ្នាក់។

ប្រការ១៥: ពេលលឺសូរកណ្តឹងរោទិ៍ សិស្សទាំងអស់ត្រូវចូលរៀនតាមថ្នាក់រៀងៗខ្លួន។ មិនអនុញ្ញាតឲ្យនៅ ខាងក្រៅថ្នាក់ក្នុងម៉ោងកំពុងសិក្សា។

ប្រការ១៦: សិស្សទាំងឡាយត្រូវខិតខំយកចិត្តទុកដាក់រៀនសូត្រ និងធ្វើកិច្ចការដែលគ្រូដាក់ឲ្យ។

ប្រការ១៧: មិនត្រូវចេញចូលថ្នាក់ដោយគ្មានការអនុញ្ញាតពីលោកគ្រូ-អ្នកគ្រូឡើយ។

ប្រការ១៨: សិស្សត្រូវចេះជួយថែរក្សាទ្រព្យសម្បត្តិសាលា និងអនាម័យឲ្យបានស្អាតជានិច្ច។ ចំពោះសិស្ស ដែលធ្វើឲ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិសាលាត្រូវទទួលខុសត្រូវ ទាំងស្រុងចំពោះចំណាត់ ការរដ្ឋបាលណាមួយរបស់សាលាជាដាច់ខាត។

ប្រការ១៩: សិស្សឈប់ឥតច្បាប់ ៣ដងក្នុងមួយខែត្រូវព្រមានផ្ទាល់មាត់ ១០ដងក្នុងមួយឆមាស ត្រូវរៀន ត្រួតថ្នាក់ និងលើសពី២០ដងត្រូវលុបឈ្មោះចេញពីសាលា។

ប្រការ២០: សិស្សដែលប្រព្រឹត្តផ្ទុយពីបទបញ្ញត្តិខាងលើ នឹងត្រូវទទួលការណែនាំពីក្រុមប្រឹក្សាវិន័យ។

# កម្មវិធីសិក្សា

កម្មវិធីសិក្សារបស់សាលាបឋមសិក្សាព្រះសហគមន៍កាតូលិកចំប៉ាចែកជាពីរដំណាក់កាល៖

- ថ្នាក់ទី១ និងទី២ យកតាមកម្មវិធីរបស់សាលារដ្ឋ (សម្រាប់ឆ្នាំ១ និងទី២) និងបញ្ជូនសិស្សទៅបន្តថ្នាក់ទី៣ នៅសាលារដ្ឋ
- ឆ្នាំទី៣ និងទី៤ មានបំប៉នវគ្គភាសាអង់គ្លេស និងកុំព្យូទ័រ (សម្រាប់សិស្សដែលបានបន្តទៅថ្នាក់ទី៣ និងទី៤សាលារដ្ឋ)។

I. **ឆ្នាំទី១ និងទី២**

**កាលវិភាគប្រចាំសប្តាហ៍ ថ្នាក់ទី១ (ពេលព្រឹក)**

| ម៉ោងសិក្សា | ច័ន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ |
|---|---|---|---|---|---|
| 6.45 - 7.00 | **គោរពទង់ជាតិ** | × | × | × | × |
| 7.00-7.40 | អប់រំកាយ | ភាសាខ្មែរ | ភាសាខ្មែរ(តែងសេចក្តី) | ភាសាខ្មែរ | អប់រំសុខភាព |
| 7.40-7.50 | ***ចេញលេង*** | | | | |
| 7.50-8.30 | ភាសាខ្មែរ | ភាសាខ្មែរ | ភាសាខ្មែរ(តែងសេចក្តី) | ភាសាខ្មែរ | ភាសាខ្មែរ |
| 8.30-8.40 | ***ចេញលេង*** | | | | |
| 8.40-9.20 | ភាសាខ្មែរ | គណិតវិទ្យា | គណិតវិទ្យា | គណិតវិទ្យា | គណិតវិទ្យា |
| 9.20-9.30 | ***ចេញលេង*** | | | | |
| 9.30-10.10 | គណិតវិទ្យា | គណិតវិទ្យា | ភាសាខ្មែរ | គណិតវិទ្យា | ភាសាខ្មែរ (សរសេរតាមអាន) |
| 10.10-10.20 | ***ចេញលេង*** | | | | |
| 10.20-11.00 | ភាសាខ្មែរ (អក្សរផ្ចង់) | វិទ្យាសាស្ត្រអនុ.សិក្សាសង្គម | វិទ្យាសាស្ត្រអនុ.សិក្សាសង្គម | ភាសាខ្មែរ | វិទ្យាសាស្ត្រអនុ.សិក្សាសង្គម |

## កំណត់សំគាល់:

- ភាសាខ្មែរ ១៣ម៉ោង គណិតវិទ្យា៧ម៉ោង វិទ្យាសាស្ត្រ និងសិក្សាសង្គម ៣ម៉ោង អប់រំកាយ និងសុខភាព២ម៉ោង។
សរុបម៉ោងសិក្សាក្នុងកម្មវិធីសិក្សា២៥ម៉ោង។

# កាលវិភាគប្រចាំសប្ដាហ៍ ថ្នាក់ទី២ (ពេលរសៀល)

| | | | | | |
|---|---|---|---|---|---|
| 1.50-2.30 | ភាសាខ្មែរ | ភាសាខ្មែរ | ភាសាខ្មែរ(តែងសេចក្ដី) | ភាសាខ្មែរ | ភាសាខ្មែរ |
| 2.30-2.40 | ចេញលេង | | | | |
| 2.40-3.20 | ភាសាខ្មែរ | គណិតវិទ្យា | គណិតវិទ្យា | គណិតវិទ្យា | គណិតវិទ្យា |
| 3.20-3.30 | ចេញលេង | | | | |
| 3.30-4.10 | គណិតវិទ្យា | គណិតវិទ្យា | ភាសាខ្មែរ(តែងសេចក្ដី) | គណិតវិទ្យា | ភាសាខ្មែរ |
| 4.10-4.20 | ចេញលេង | | | | |
| 4.20-5.00 | អប់រំកាយ | វិទ្យាសាស្ត្រអនុ.សិក្សាសង្គម | វិទ្យាសាស្ត្រអនុ.សិក្សាសង្គម | ភាសាខ្មែរ | អប់រំសុខភាព |
| | × | × | × | × | **គោរពទង់ជាតិ** |

**កំណត់សំគាល់:**

- ភាសាខ្មែរ ១៣ម៉ោង គណិតវិទ្យា៧ម៉ោង វិទ្យាសាស្ត្រ និងសិក្សាសង្គម ៣ម៉ោង អប់រំកាយ និងសុខភាព២ម៉ោង។ សរុបម៉ោងសិក្សាក្នុងកម្មវិធីសិក្សា២៥ម៉ោង។

# I.ឆ្នាំទី៣ និងទី៤

**បំណែកចែកកម្មវិធីសិក្សា ២០១៥-២០១៦**
**មុខវិជ្ជា:កុំព្យូទ័រ-ថ្នាក់ទី៣**

| ខែ | សប្តាហ៍ | ម៉ោង | ចំណងជើងមេរៀន | ភាគរយ % |
|---|---|---|---|---|
| តុលា | 4 | 8 | I. **មូលដ្ឋានគ្រឹះរបស់កុំព្យូទ័រ**<br>១.និយមន័យកុំព្យូទ័រ(Computer)<br>២) ប្រវត្តិកុំព្យូទ័រ.History of Computer) | 10.31 |
| វិច្ឆិកា | 4 | 8 | **មូលដ្ឋានគ្រឹះរបស់កុំព្យូទ័រ**<br>៣.របៀបបើកកុំព្យូទ័រ (Turn on computer)<br>៤.របៀបបិទកុំព្យូទ័រ (Shutdown Computer)<br>៥ការណែនាំសិស្សស្គាល់ពីឧបករណ៍របស់កុំព្យូទ័រ.(Computer) | 21.39 |
| ធ្នូ | 4 | 8 | **កម្មវិធី** Typing Skill<br>១.របៀបចូលកម្មវិធី Typing<br>២ របៀបដាក់ម្រាមដៃក្នុងការវាយ.Typing<br>៣ ការចាកចេញពីកម្មវិធី.Typing | 32.47 |
| មករា | 4 | 8 | ៤.ការវាយអក្សរខ្មែរក្នុងកម្មវិធី Typing<br>៥ការវាយអក្សរ.អង់គ្លេសក្នុងកម្មវិធី Typing | 43.55 |
| កុម្ភៈ | 4 | 8 | **ការណែនាំក្នុងកម្មវិធី** Paint<br>១ របៀបបើកកម្មវិធី.Paint (Open)<br>-ការណែនាំសិស្សឲ្យគូររូបភាពផ្សេងៗ<br>២ របៀបបិទកម្មវិធី.Paint (Close) | 54.63 |
| មិនា | 4 | 8 | -**ការកែសំរួលថ្ងៃ ខែឆ្នាំ និង ម៉ោង** Date and Time<br>១របៀបចូលកែសំរួល. Date and Time<br>២ របៀបចូលមើល.Icon ( Date and time )<br>-ការវាយកម្មវិធី Typing | 65.71 |

| | | | | |
|---|---|---|---|---|
| មេសា | 2 | 4 | **-ការណែនាំអំពីផ្ទាំង Desktop របស់កុំព្យូទ័រ**<br>១ របៀបប្តូររូបភាពនៅលើផ្ទាំង.Desktop របស់ Windows<br>២ របៀបដាក់.Screen Saver Desktop របស់ផ្ទាំង Windows<br>-ការវាយកម្មវិធី Typing | 71.25 |
| ឧសភា | 4 | 8 | **របៀបប្តូរ Style Mouse ក្នុងការប្រើប្រាស់**<br>១ របៀបចូលកំណត់.Style Mouse<br>២ របៀបជ្រើសរើសប្រភេទ.Style របស់ Mouse<br>-ការវាយកម្មវិធី Typing | 82.33 |
| មិថុនា | 4 | 8 | ១ ការណែនាំសិស្សស្គាល់ពីអំពី.Icon ក្នុងកុំព្យូទ័រ<br>២ ការបើករូបភាពក្នុងកម្មវិធី.Microsoft office Picture manager<br>-ប្រាប់ពីរបៀបចូលកម្មវិធី (Open)<br>-ប្រាប់ពីរបៀបបិទកម្មវិធី )Close)<br>-ការវាយកម្មវិធី Typing | 93.41 |
| កក្កដា | 2 | 4 | **រំលឹកមេរៀនឡើងវិញ** | 98.95 |

# បំណែកចែកកម្មវិធីសិក្សា ២០១៦-២០១៧
# មុខវិជ្ជា:កុំព្យូទ័រ-ថ្នាក់ទី៤

| ខែ | សប្តាហ៍ | ម៉ោង | ចំណងជើងមេរៀន | ភាគរយ% |
|---|---|---|---|---|
| តុលា | 4 | 8 | **មូលដ្ឋានគ្រឹះរបស់កុំព្យូទ័រ**<br>៣.របៀបបើកកុំព្យូទ័រ (Turn on computer)<br>៤.របៀបបិទកុំព្យូទ័រ (Shutdown Computer)<br>៥ការណែនាំសិស្សស្គាល់ពីឧបករណ៍របស់កុំព្យូទ័រ.(Computer( | 10.31 |
| វិច្ឆិកា | 4 | 8 | **កម្មវិធី Typing Skill**<br>១.របៀបចូលកម្មវិធី Typing<br>២ របៀបដាក់ម្រាមដៃក្នុងការវាយ.Typing<br>៣ ការចាកចេញពីកម្មវិធី.Typing | 21.39 |
| ធ្នូ | 4 | 8 | ៤.ការវាយអក្សរខ្មែរក្នុងកម្មវិធី Typing<br>៥ការវាយអក្សរ.អង់គ្លេសក្នុងកម្មវិធី Typing | 32.47 |
| មករា | 4 | 8 | ៤.ការវាយអក្សរខ្មែរក្នុងកម្មវិធី Typing<br>៥ការវាយអក្សរ.អង់គ្លេសក្នុងកម្មវិធី Typing | 43.55 |
| កុម្ភៈ | 4 | 8 | **វិធីបើក មិន ICON**<br>**ពង្រីកបង្រួម MAXIMIZE OR MINIMIZE**<br>**ម៉ាស៊ីនគិតលេខ CULCULATOR** | 54.63 |
| មិនា | 4 | 8 | **តើ MS Word គឺជាកម្មវិធីផ្នែកអ្វី?**<br>វិធីចាប់ផ្តើមកម្មវិធី -Word for windows?<br>- របៀបចាកចេញពីកម្មវិធី Word for windows? | 65.71 |
| មេសា | 2 | 4 | **ការវាយអត្ថបទ How to create document ?**<br>- Typing simple word<br>- Typing simple phrases | 71.25 |

| | | | | |
|---|---|---|---|---|
| ឧសភា | 4 | 8 | - Typing simple phrases<br>**របៀបរក្សាឯកសារទុក** How to save document ? | 82.33 |
| ?<br>មិថុនា | 4 | 8 | **របៀបបើក** Video **ក្នុងកម្មវិធី** ) Window Media Player )<br>១ របៀបបើកកម្មវិធី.Videos (Open)<br>២ របៀបបិទកម្មវិធី.Videos (Close)<br>ការវាយកម្មវិធី Typing | 93.41 |
| កក្កដា | 2 | 4 | **រំលឹកមេរៀនឡើងវិញ** | 98.95 |

# បំណែកចែកកម្មវិធីសិក្សា ២០១៥-២០១៦

**មុខវិជ្ជា: អង់គ្លេស** ( English for children )-**ថ្នាក់ទី៣**

| ខែ | សប្តាហ៍ | ម៉ោង | ចំណងជើងមេរៀន | ភាគរយ% |
|---|---|---|---|---|
| តុលា | 4 | 8 | <u>Lesson 1: The ABC song</u><br>- Pre-singing<br>- Take turn to singing<br><u>Lesson 2: Letters A to E</u><br>- Pre-reading<br>- Pre-writing | 10.31 |
| វិច្ឆិកា | 4 | 8 | <u>Lesson 3: Revising What's this?</u><br>- Name some objects (book, car, apple, door…)<br><u>Lesson 4: F to K</u><br>- Allow the Ss to say about letter F to K<br>- Tell the Ss about the word start with Letter F to K | 21.39 |
| ធ្នូ | 4 | 8 | <u>Lesson 5: Revising (What do you see?)</u><br>- About (flag, ice-cream, hand, girl, jelly, key…)<br><u>Lesson 6: L to P</u><br>- Allow the Ss to say about letterL toP<br>- Tell the Ss about the word start with Letter L to P<br>- Take turn to write the letters<br>- Telling each other about the letters | 32.47 |
| មករា | 4 | 8 | <u>Lesson 7: Revision (What can you see?)</u><br>- Leg, nose, orange, mouth, pencil …<br><u>Lesson 8: Letter Q to S</u><br>Allow the Ss to say about letterL toP | 43.55 |

| | | | | |
|---|---|---|---|---|
| | | | - Tell the Ss about the word start with Letter L to P<br>- Take turn to write the letters<br>- Telling each other about the letters<br>- Coloring the pictures | |
| កុម្ភៈ | 4 | 8 | **<u>Lesson 9: Revision (Who can spell)</u>**<br>- Allow the Ss to spell some words you taught<br>- Show some pictures with the words<br>**<u>Lesson 10: Letters T to W</u>**<br>- Write on the white board and ask Ss to spell<br>- Print out the letter and allow the Ss to color<br>- take turn to read some words related the letter T to W | 54.63 |
| មិនា | 4 | 8 | **<u>Lesson 11: Revision (Is this yours?)</u>**<br>- Show the objects that belong to Ss<br>- Allow the Ss to ask each other about their belonging<br>**<u>Lesson 12: Letter X  to Z</u>**<br>- Write on the white board and ask Ss to spell<br>- Print out the letter and allow the Ss to color<br>- take turn to read some words related the | 65.71 |

| | | | | |
|---|---|---|---|---|
| ឧសភា | 4 | 8 | Lesson 13: Numbers (1 to 10)<br>- Counting number 1 to 10<br>- Pre-counting<br>- Number 10 to 100<br>- Sing a song | 82.33 |
| មិថុនា | 4 | 8 | Lesson 14: How many...?<br>- Know about the mummer | 93.41 |
| កក្កដា | 2 | 4 | Lesson 15: Revision A to Z | 98.95 |

**បំនែកចែកកម្មវិធីសិក្សា ២០១៦-២០១៧**

**មុខវិជ្ជា: អង់គ្លេស** ( English book from the ministry of education ) **ថ្នាក់ទី៤**

| ខែ | សប្តាហ៍ | ម៉ោង | ចំណងជើងមេរៀន | ភាគរយ% |
|---|---|---|---|---|
| តុលា | 4 | 8 | Unit 1 : Greeting<br>**Lesson 1: Hello!**<br>- Greeting each other<br>**Lesson 2: My name is ...**<br>- Introducting youself and others<br>**Lesson 3: How old are you?**<br>- Asking and answering about personal thing<br>**Lesson 4: Review**<br>- Greeting someone<br>- Talking about name and age | 10.31 |

| | | | | |
|---|---|---|---|---|
| វិច្ឆិកា | 4 | 8 | **Unit 2: Things**<br>**Lesson 1: What is this?**<br>- Talking about things?<br>**Lesson 2: Is this a pen?**<br>- Talking about things and animal<br>**Lesson 3: Is this a cake?**<br>- Talking about things<br>**Lesson 4: Review**<br>- Talking about things and animals | 21.39 |
| ធ្នូ | 4 | 8 | **Unit 3: Animals**<br>**Lesson 1: This is cat.**<br>- Asking and answering about animals<br>**Lesson 2: Is this a cat?**<br>- Asking and answering about animals<br>**Lesson 3: Is this your…?**<br>- Asking and answering about animals of possession<br>**Lesson 4: Review**<br>- Asking and answering about animals & possession | 32.47 |
| មករា | 4 | 8 | **Unit 4: Nationality**<br>**Lesson 1: My nationality is …**<br>- Talking about nationality<br>Lesson 2: Are you Cambodia?<br>- Talking about nationality<br>Lesson 3: Is she Chinese? | 43.55 |

| | | | | |
|---|---|---|---|---|
| កុម្ភៈ | 4 | 8 | **Unit 5: How many ...?**<br>**Lesson 1: There is a ...**<br>- Describing and asking about singular noun<br>**Lesson 2: There are**<br>- Describing and asking about plural noun<br>**Lesson 3: How many ...?**<br>- Describing and asking about the number of things/animals<br>**Lesson 4: Review**<br>- Describing and asking and about singular and plural nouns | 54.63 |
| មិនា | 4 | 8 | **Unit 6: Jobs**<br>**Lesson 1: What are you?**<br>- Talking about a person's job<br>**Lesson 2: What is she?**<br>- Talking about grade | 65.71 |
| មេសា | 2 | 4 | **Lesson 3: What is your mother's job?**<br>- Talking about parents' job<br>**Lesson 4: Review**<br>- Talking about job and grade | 71.25 |
| ឧសភា | 4 | 8 | **Unit 7: Family**<br>**Lesson 1: Sok's wife**<br>- Talking about husband and wife in a family<br>**Lesson 2: Sok's children** | 82.33 |

| | | | | |
|---|---|---|---|---|
| | | | - Talking about member in a family<br>**Lesson 4: Review**<br>- Talking about member in a family | |
| មិថុនា | 4 | 8 | <u>**Unit 8: Daily Activities**</u><br>**Lesson 1: At home**<br>- Talking about activities<br>**Lesson 2: In the classroom**<br>- Talking about classroom's instruction<br>**Lesson 3: At break time**<br>- Talking about the break time activities<br>**Lesson 4: Review**<br>- Talking about daily activities | 93.41 |
| កក្កដា | 2 | 4 | **Review the lesson** | 98.95 |

# ស្ថិតិសិស្សថ្នាក់ទី១ ទី២ និង សិស្សទៅរៀនបន្តជាមួយសាលារដ្ឋ ឆ្នាំសិក្សាថ្មី ២០១៥-១៦

| ល-រ | គោត្តនាម- នាម | សាលា | ពេលវេលា | ថ្នាក់ទី ១ | | ថ្នាក់ទី ២ | | សិស្សឆ្នាំសិក្សាថ្មី | | | សិស្សទៅសាលារដ្ឋ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ស្រី | សរុប | ស្រី | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | |
| 01 | លោកតុត សុធា | ចំប៉ា | $07^{h}00 – 11^{h}00$នាទី ព្រឹក | | | 14 | 29 | 25 | 38 | 63 | 13 | 9 | 22 | ចូលរៀនបន្តថ្នាក់ទី៣ |
| 02 | លោកធន់ សារឿត | | $13^{h}00 – 17^{h}00$នាទី ល្ងាច | 11 | 34 | | | | | | | | | |
| 03 | លោកនុត ចន្ធា | ទួលតាំង | $13^{h}00 – 17^{h}00$នាទី ល្ងាច | 14 | 25 | | | 14 | 11 | 25 | 9 | 10 | 19 | ចូលរៀនបន្តថ្នាក់ទី២ |
| 04 | អ្នកស្រីអ៊ុ សុខា | កោះនរា | $07^{h}00 – 11^{h}00$នាទី ព្រឹក | 12 | 23 | | | 23 | 28 | 51 | 13 | 8 | 21 | ចូលរៀនបន្តថ្នាក់ទី៣ |
| 05 | អ្នកស្រីជិន សុលី | | $13^{h}00 – 17^{h}00$នាទី ល្ងាច | | | 11 | 28 | | | | | | | |
| 06 | អ្នកស្រីអែម សារ៉ាត | ពោងចក្រ | $07^{h}00 – 11^{h}00$នាទី ព្រឹក | | | 9 | 21 | 14 | 27 | 41 | 5 | 9 | 14 | ចូលរៀនបន្តថ្នាក់ទី៣ |
| 07 | អ្នកស្រីប៉ែន ចន្ទណា | | $13^{h}00 – 17^{h}00$នាទី ល្ងាច | 5 | 20 | | | | | | | | | |
| 08 | អ្នកស្រីអឿន ចំណាប់ | ផ្លូវត្រី | $07^{h}00 – 11^{h}00$នាទី ព្រឹក | 14 | 21 | | | 25 | 21 | 46 | 10 | 8 | 18 | ចូលរៀនបន្តថ្នាក់ទី៣ |
| 09 | អ្នកស្រីទិត្យ ស្រីពៅ | | $13^{h}00 – 17^{h}00$នាទី ល្ងាច | | | 11 | 25 | | | | | | | |
| 10 | កញ្ញាប៉ែន ចាន់ធឿន | កំពង់ចម្លង | $07^{h}00 – 11^{h}00$នាទី ព្រឹក | 10 | 27 | | | 26 | 27 | 53 | 9 | 11 | 20 | ចូលរៀនបន្តថ្នាក់ទី៣ |
| 11 | អ្នកស្រីយិន សំអាត | | $07^{h}00 – 11^{h}00$នាទី ព្រឹក | | | 16 | 26 | | | | | | | |
| 12 | កញ្ញាឆាយ ដាវ៉ា | ព្រែកដាច់ | $07^{h}00 – 11^{h}00$នាទី ព្រឹក | 6 | 13 | | | 6 | 7 | 13 | 12 | 5 | 17 | ចូលរៀនបន្តថ្នាក់ទី៣ |
| 13 | កញ្ញាសន ណារី | សំពោងធំ | $07^{h}00 – 11^{h}00$នាទី ព្រឹក | | | 14 | 24 | 20 | 19 | 39 | 10 | 8 | 18 | ចូលរៀនបន្តថ្នាក់ទី៣ |
| 14 | លោកសោម វិជិត | | $13^{h}00 – 17^{h}00$នាទី ល្ងាច | 6 | 15 | | | | | | | | | |
| 15 | លោកឌី វណ្ណឌីត | បឹងឈូក | $13^{h}00 – 17^{h}00$នាទី ល្ងាច | 11 | 21 | | | 22 | 20 | 42 | 5 | 4 | 9 | ចូលរៀនបន្តថ្នាក់ទី៣ |
| 16 | លោកខាន់ ប៊ុនធឿន | | $13^{h}00 – 17^{h}00$នាទី ល្ងាច | | | 11 | 21 | | | | | | | |
| 17 | អ្នកស្រីឡេង លីដា | ទួលក្រសាំង | $07^{h}00 – 11^{h}00$នាទី ព្រឹក | 13 | 26 | | | 13 | 13 | 26 | 8 | 5 | 13 | ចូលរៀនបន្តថ្នាក់ទី៣ |
| 18 | លោកង៉ាន់ សេងឡាយ | ស្អាង | $13^{h}00 – 17^{h}00$នាទី ល្ងាច | 9 | 22 | | | 9 | 13 | 22 | 7 | 9 | 16 | ចូលរៀនបន្តថ្នាក់ទី៣ |
| 19 | កញ្ញាឱវ សុម៉ាលី | សំប៉ាន | $07^{h}00 – 11^{h}00$នាទី ព្រឹក | 18 | 41 | | | 34 | 45 | 79 | 14 | 13 | 27 | ចូលរៀនបន្តថ្នាក់ទី៣ |
| 20 | លោកហង់ ស៊ីម៉ូ | | $07^{h}00 – 11^{h}00$នាទី ព្រឹក | | | 16 | 38 | | | | | | | |
| 21 | លោកហែម ថៃ | ជ្រៃធំ | $13^{h}00 – 17^{h}00$នាទី ល្ងាច | 8 | 25 | | | 14 | 27 | 41 | 12 | 4 | 16 | ចូលរៀនបន្តថ្នាក់ទី៣ |
| 22 | លោកហ៊ុយ យូងន | | $13^{h}00 – 17^{h}00$នាទី ល្ងាច | | | 6 | 16 | | | | | | | |
| 23 | ? | ស្វាយប៉ាក | ? | 16 | 40 | | | 16 | 24 | 40 | | | | |
| **សរុបរួម:** | | | | 153 | 353 | 108 | 228 | 261 | 320 | 581 | 127 | 103 | 230 | |

# រូបថតរបស់សាលា



ថ្នាក់ទី១ (វេនព្រឹក)

# រូបថតរបស់សាលា



ថ្នាក់ទី២( ពេនរសៀល )

# ទីចាត់ការ



# សាលប្រជុំ



# គោរពទង់ជាតិ



## ទំនាក់ទំនងការិយាល័យ

ផ្ទះលេខ៨៦៨, ផ្លូវ ៩៦P, ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ

រាជធានីភ្នំពេញ

**លេខទូរស័ព្ទ ៖** 023 6400841 / 089474995

**អ៊ីម៉ែល :** apostolicvicariate.phnompenh@gmail.com